ភ្នំពេញ ប៉ុស្តិ៍ ថ្ងៃអង្គារ ទី១២ ខែតុលា ឆ្នាំ២០១០ ៧

ព័ត៌មានជាតិ

ទស្សនវិទូល្បីឈ្មោះម្នាក់ នៅតែខឹងសហរដ្ឋអាមេរិក ដែលទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា

«លោក Henry Kissinger មេបញ្ជាការកងទ័ពសហរដ្ឋអាមេរិក សមណាស់តែត្រូវនាំខ្លួនយកទៅកាត់ទោស ចំពោះតួនាទីរបស់គាត់ ក្នុងការទម្លាក់គ្រាប់បែក នៅកម្ពុជា ប្រសិនបើពិភពលោក ត្រូវបានគ្រប់គ្រងដោយប្រព័ន្ធយុត្តិធម៌ មិនមែនដោយកម្លាំងទេនោះ»។

Stuart Alan Becker

លោកណូអាម ឈុំស្គី កាលពីសម័យសង្គ្រាមនៅវៀតណាម។ រូបថត សហការី

លោក ណូអាម ឈុំស្គី ទស្សនវិទូ និងជាអ្នកភាសាវិទូ ថ្លែងថា សហរដ្ឋអាមេរិក ជំពាក់ពាក្យសុំទោស ចំពោះប្រទេសកម្ពុជា ព្រមទាំងជំពាក់សំណងដ៏ច្រើនផងដែរ ដោយសារយុទ្ធនាការទម្លាក់គ្រាប់បែក បេ-៥២ ហៅថា Operation Menu ដែលបានសម្លាប់ប្រជាពលរដ្ឋខ្មែរ រហូតដល់ទៅ ១ លាននាក់។ លោក ឈុំស្គី បញ្ជាក់ថា យុទ្ធនាការ ដែលចាប់ផ្តើមពីថ្ងៃទី ១៨ មីនាឆ្នាំ ១៩៦៩ ដល់ថ្ងៃទី ២៦ ឧសភាឆ្នាំ ១៩៧០ បានបំផ្លិចបំផ្លាញទីក្រុង និងភូមិចំនួនប្រហែល ១០០០ កន្លែង និងបានធ្វើឲ្យប្រជាជន ២ លាននាក់ផ្លាស់ប្តូរទីលំនៅ និងបានជួយឲ្យរបបខ្មែរក្រហមបានឡើងកាន់អំណាច។

ការអត្ថាធិប្បាយរបស់លោក ឈុំស្គី បានធ្វើឡើងបន្ទាប់ពីសហរដ្ឋអាមេរិក បានច្រានចោល កាលពីសប្តាហ៍មុន នូវពាក្យស្នើសុំពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលសុំឲ្យលុបចោលបំណុលចំនួន ៣១៧ លានដុល្លារអាមេរិក ដែលរបបលោក លន់ នល់ បានជំពាក់សហរដ្ឋអាមេរិក ក្នុងអំឡុងទសវត្សរ៍ទី៧០។

ក្នុងបទសម្ភាសមួយ លោក ឈុំស្គី បានលើកឡើងថា៖ « លោក Henry Kissinger សមណាស់តែត្រូវនាំខ្លួនយកមកកាត់ទោស ចំពោះតួនាទីរបស់គាត់ នៅក្នុងការទម្លាក់គ្រាប់បែកដ៏ច្រើនសម្បើម មកលើប្រទេសកម្ពុជា ប្រសិនបើពិភពលោកនេះ ត្រូវបានគ្រប់គ្រងដោយប្រព័ន្ធយុត្តិធម៌ មិនមែនដោយកម្លាំងទេនោះ»។ លោក ឈុំស្គី ត្រូវបានគេចាត់ទុកថា ជាបិតាផ្នែកភាសាសាស្ត្រ នាសម័យទំនើបនេះ ហើយជាអ្នកនិពន្ធសៀវភៅជាង ១០០ ក្បាល ស្តីពីភាសា និងទំនាក់ទំនងអន្តរជាតិ។ លោកក៏ជាបញ្ញវន្តម្នាក់ ដែលត្រូវគេស្រង់សម្តីច្រើនបំផុតផងដែរ។ ពាក្យសម្តីរបស់លោក ដែលថ្លែងក្នុងសុន្ទរ-កថា បទសម្ភាស និងសៀវភៅផ្សេងៗ ត្រូវបានបកប្រែជាច្រើនភាសា ភ្លាមៗ ក្រោយពីការចុះផ្សាយ។

ក្នុងខណៈដែលលោក ឈុំស្គី ឈានចូលអាយុ ៨៣ ឆ្នាំ នៅឆ្នាំនេះ លោកនៅតែជាសាស្ត្រាចារ្យកិត្តិយសម្នាក់ នៅឯវិទ្យាស្ថាន Massachusetts Institute of Technology ក្នុងទីក្រុង Cambridge រដ្ឋ Massachusetts សហរដ្ឋអាមេរិក ដែលជាសាកលវិទ្យាល័យបច្ចេកទេសមួយដ៏ល្អបំផុត នៅលើពិភពលោក។ លោក ឈុំស្គី បានបង្ហាត់បង្រៀននៅវិទ្យាស្ថាននោះ អស់រយៈពេលជាង ៥០ ឆ្នាំមកហើយ។ ការសិក្សាស្រាវជ្រាវរបស់លោក ស្តីពីថា តើខួរក្បាលពាក់ព័ន្ធទៅនឹងភាសាយ៉ាងដូចម្តេចនោះ បានផ្លាស់ប្តូររបៀបដែលសាស្ត្រាចារ្យ នៅលើសកលលោក គិតអំពីចិត្តវិទ្យា អាកប្ប-កិរិយា និងការសិក្សាស្រាវជ្រាវទាំងមូល ស្តីពីគំនិតខួរក្បាលរបស់មនុស្ស។

វិធីសាស្ត្ររបស់លោក ឈុំស្គី លើការសិក្សាស្រាវជ្រាវពីគំនិត និងវិទ្យាសាស្ត្រ ប្រកាន់យកនូវទស្សនៈថា មនុស្សមានហ្សែនកំណត់គួរឲ្យកត់សម្គាល់ ពីឪពុកម្តាយរបស់ពួកគេ ដែលជាប្រព័ន្ធដ៏ស្មុគស្មាញ ដែលម៉ាស៊ីនកុំព្យូទ័រជាច្រើន មិនអាចចម្លងដូចបានឡើយ ហើយនោះជាអ្វីដែលធ្វើឲ្យមនុស្សយើង មានតម្លៃដូច្នេះ។ ឥឡូវនេះ ទ្រឹស្តីរបស់លោក ឈុំស្គី ស្តីពីវេយ្យាករណ៍ជាលក្ខណៈសកល (Universal Grammar) និងវេយ្យាករណ៍ដែលជាការបង្កើតឡើង (Generative Grammar) ត្រូវបានទទួលស្គាល់ និងទទួលយកដោយបញ្ញវន្តនានា នៅទូទាំងពិភពលោក ហើយជាទ្រឹស្តីដែលលើកឡើងថា គ្រប់ភាសារបស់មនុស្សទាំងអស់ គឺផ្អែកលើវិធានជាមូលដ្ឋាន ដែលរាល់ទារកទាំងអស់ បានចាប់កំណើតយកមកជាមួយ។ ទ្រឹស្តីនេះ បានពន្យល់ពីមូលហេតុដែលកុមារ ចេះភាសា ដែលគេនិយាយមកកាន់ខ្លួន យ៉ាងឆាប់រហ័ស ទោះបីជានៅតំបន់ណាក៏ដោយ។

លោក ឈុំស្គី បានលើកឡើងថា ប្រសិនបើមនុស្សភពក្រៅ មកកាន់ពិភពលោកយើងនេះ មនុស្សភពក្រៅនោះ នឹងសង្កេតឃើញថា មនុស្សទាំងអស់និយាយភាសាតែមួយ ដែលមានលក្ខណៈខុសគ្នាតិចតួច។ វិធីសាស្ត្រស្វែងយល់ពីភាសារបស់លោក ឈុំស្គី បានជួយឲ្យអ្នកវិទ្យាសាស្ត្រផ្នែកកុំព្យូទ័រ និងអ្នកស្រាវជ្រាវក្នុងវិស័យផ្សេងៗជាច្រើនទៀត យកវិធានបែបគណិតវិទ្យា មកអនុវត្តលើភាសា។

បណ្ឌិត Niels Jerne សាស្ត្រាចារ្យជនជាតិអង់គ្លេស បានឈ្នះរង្វាន់ណូបែលក្នុងឆ្នាំ ១៩៦៤ ដោយយកទ្រឹស្តីរបស់លោក ឈុំស្គី ទៅអនុវត្តលើប្រព័ន្ធផ្សាំ នៃរូបរាងកាយមនុស្ស ក្នុងឯកសារស្រាវជ្រាវមួយ ដែលមានចំណងជើងថា «Generative Grammar of the Immune System»។

ក្រៅពីទស្សនៈនាំមុខ ផ្នែកចិត្តសាស្ត្រ និងភាសាសាស្ត្រ លោក ឈុំស្គី ក៏ជាអ្នកប្រឆាំងនឹងសង្គ្រាមវៀតណាម នាពេលដំបូង ដែលកើតឡើង ចាប់តាំងពីពេលបារាំងងើបខ្លួនឡើងវិញ នៅតាមបណ្តាប្រទេសឥណ្ឌូចិន ក្រោយពីសង្គ្រាមលោកលើកទី ២ បានបញ្ចប់ក្នុងឆ្នាំ១៩៤៥។ លោកជាកម្លាំងបញ្ញវន្តម្នាក់ នៅពីក្រោយចលនាប្រឆាំងសង្គ្រាម ក្នុងសហរដ្ឋអាមេរិក នៅអំឡុងទសវត្សទី ៦០ និងដើមទសវត្សទី ៧០។ លោក ឈុំស្គី ក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញផងដែរ ដោយសារលោករិះគន់គោលនយោបាយការបរទេសរបស់រដ្ឋនានា ជាពិសេសរបស់សហរដ្ឋអាមេរិក ជាប្រទេសដែលលោកកំពុងរស់នៅនិងកាន់សញ្ជាតិ។ លោកបានជួយមនុស្សឲ្យប្រកាន់យក«គំនិតស្វ័យការពារ» ដោយចង្អុលបង្ហាញពីភាពខុសគ្នារវាងពាក្យសម្តី និងទង្វើរបស់អ្នកនយោបាយ មន្ត្រីរដ្ឋាភិបាល មន្ត្រីសាសនា ឬបុគ្គលិកក្រុមហ៊ុន ដូច្នេះ ប្រជាពលរដ្ឋសាមញ្ញ អាចយល់ដឹងពីពិភពលោកកាន់តែច្បាស់ថែមទៀត ក្នុងខណៈដែលពួកគេចង្អុលបង្ហាញពីភាពខុសគ្នានេះ។ លោកបានទាញហេតុផលថា សង្គ្រាមវៀតណាម មិនមែនជាផលប្រយោជន៍របស់ប្រជាជនអាមេរិកទេ ហើយលោកក៏បានផ្តល់មូលហេតុផងដែរថា គោលនយោបាយរបស់ប្រទេសអ៊ីស្រាអែល នៅតំបន់ West Bank និង Gaza មិនមែនជាផលប្រយោជន៍ របស់ប្រជាពលរដ្ឋអ៊ីស្រាអែលនោះទេ។

លោក ឈុំស្គី បានតាមដានព្រឹត្តិការណ៍ក្នុងប្រទេសកម្ពុជា ចាប់តាំងពីពេលសង្គ្រាមលោកលើកទី ២ បានបញ្ចប់មក។ លោកបានចំណាយពេលឆ្លើយសំណួរមួយចំនួន ស្តីពីព្រឹត្តិការណ៍សំខាន់ៗ ក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានជួយបង្កើតរូបរាងប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ។

តើហេតុដូចម្តេច បានជាគេយល់ថា លោកមិនសូវរិះគន់ ពីអំពើដ៏ព្រៃផ្សៃ របស់របបខ្មែរក្រហម ដោយសារសៀវភៅឆ្នាំ ១៩៨៨ មានចំណងជើងថា Manufacturing Consent ដែលជាស្នាដៃនិពន្ធរបស់លោក និងលោក Edward S Herman នោះ?

នៅក្នុងសៀវភៅឆ្នាំ ១៩៨៨ ខ្ញុំ និងលោក Herman បានត្រួតពិនិត្យ ពីវិធីដែលគេចាត់ទុកឧក្រិដ្ឋកម្មព្រៃផ្សៃ នៅក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលបីដំណាក់កាលផ្សេងៗគ្នា គឺសម័យសង្គ្រាមសហរដ្ឋអាមេរិក មុនពេលខ្មែរក្រហមឡើងកាន់អំណាចនៅខែមេសា ១៩៧៥ សម័យខ្មែរក្រហម និងសម័យបន្ទាប់ពីវៀតណាមឈ្លានពាន និងបណ្តេញខ្មែរក្រហមចេញពីអំណាច ហើយពេលនោះសហរដ្ឋអាមេរិក និងអង់គ្លេស បែរជាជួយឧបត្ថម្ភផ្នែកយោធា និងការទូត ដល់ខ្មែរក្រហម «របបកម្ពុជាប្រជាធិបតេយ្យ» ទៅវិញ។ រហូតដល់ពេលយើងសរសេរសៀវភៅនេះ មានការយល់ដឹងថា សង្គ្រាមអាមេរិកមុនឆ្នាំ ១៩៧៥ មានលក្ខណៈព្រៃផ្សៃ ប៉ុន្តែទើបតែក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយប៉ុណ្ណោះ ដែលឯកសារលម្អិត ត្រូវបានចេញផ្សាយ។ ឥឡូវនេះ យើងដឹងថា ដំណាក់កាលដ៏ព្រៃផ្សៃបំផុត ចាប់ផ្តើមក្នុងឆ្នាំ ១៩៧០ នៅពេលលោក Henry Kissinger បានបញ្ជូនបញ្ជារបស់លោកប្រធានាធិបតី Nixon ឲ្យ «ទម្លាក់គ្រាប់បែកដ៏ច្រើនសម្បើម មកលើប្រទេសកម្ពុជា។ វាពិបាកក្នុងការស្វែងរកសេចក្តីប្រកាស ដែលមានគោលបំណងប្រល័យពូជសាសន៍ ក្នុងកំណត់ត្រាប័ណ្ណសាររបស់រដ្ឋ ហើយការទម្លាក់គ្រាប់បែក ត្រូវបានអនុវត្ត។ ការទម្លាក់គ្រាប់បែកនៅតាមទីជនបទ នៃប្រទេសកម្ពុជា ជាកម្រិតដូចក្រុមប្រទេសសម្ព័ន្ធមិត្ត បានទម្លាក់គ្រាប់បែក នៅតំបន់ប៉ាស៊ីហ្វិក ក្នុងអំឡុងសង្គ្រាមលោកលើកទី ២ អ៊ីចឹង។ នៅពេលពួកខ្មែរក្រហម បានកើនឡើងដល់ចំនួនប្រហែល ២០ ម៉ឺននាក់ ដែលត្រូវបានជ្រើសរើស ឲ្យចូលរួមក្នុងចលនា ដោយសារការទម្លាក់គ្រាប់បែក ដែលជាមូលហេតុចម្បង។ ក្នុងអំឡុងសម័យទី ១ និងទី ៣ អាមេរិក ដែលគេស្គាល់ជាទូទៅថា ជាពួកបស្ចិមប្រទេស មានសកម្មភាពជាច្រើន ដែលអាមេរិកអាចធ្វើ។ ក្នុងអំឡុងសម័យទី ២ ពុំមានអ្នកណា មានយោបល់ថា តើគួរធ្វើសកម្មភាពអ្វីនោះទេ។ ការផ្សព្វផ្សាយវិញ មានលក្ខណៈផ្ទុយពីអ្វី ដែលសីលធម៌ជាមូលដ្ឋាន អាចនឹងកំណត់ឡើង។ ក្នុងអំឡុងសម័យទី ១ មានការតវ៉ាមួយចំនួន ប៉ុន្តែការផ្សព្វផ្សាយ មានលក្ខណៈតិចតួច ហើយវាត្រូវបានគេបំភ្លេចយ៉ាងឆាប់រហ័ស។ ការបញ្ចេញព័ត៌មានថ្មីៗ ស្ទើរតែត្រូវបានគេទប់ស្កាត់ទាំងស្រុង។ ក្នុងអំឡុងសម័យទី ៣ ការផ្សព្វផ្សាយមានលក្ខណៈតិចតួចផងដែរ ហើយប្រវត្តិសាស្ត្រ ត្រូវបានគេបំភ្លេចស្ទើរទាំងស្រុង។ ការពិនិត្យដ៏ត្រឹមត្រូវរបស់យើង លើព្រឹត្តិការណ៍ទាំងនេះ ពិតជាបាននាំទៅឲ្យឃើញពីអំពើព្រៃផ្សៃ និងពាក្យកុហកជាច្រើន ដូចអ្វីដែលអ្នកបានលើកឡើងអ៊ីចឹង។ ការពិនិត្យកាន់តែមានលក្ខណៈពិតប្រាកដថែមទៀត មាននៅក្នុងការសិក្សាស្រាវជ្រាវពីរភាគរបស់យើង កាលពីឆ្នាំ ១៩៧៩ ដែលមានចំណងជើងថា «Political Economy of Human Rights» ដែលផ្តល់ជាឯកសារលម្អិត បង្ហាញពីលំនាំព្រឹត្តិការណ៍ ដែលបានកើតឡើងនៅទូទាំងពិភពលោក។ ការសិក្សាភាគច្រើន ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋកម្មរបស់សហរដ្ឋអាមេរិក។

ជំពូកទី ១ ក្នុងសៀវភៅនោះ គឺនិយាយពីប្រទេសកម្ពុជា។ យើងបានថ្កោលទោសឧក្រិដ្ឋកម្មរបស់ ប៉ុល ពត យ៉ាងខ្លាំងៗ ហើយក៏បានបង្ហាញពីការបំភ្លៃការពិត ការបោកប្រាស់ផងដែរ។ យើងបានសរសេរថា ឧក្រិដ្ឋកម្មមានលក្ខណៈព្រៃផ្សៃណាស់ ប៉ុន្តែអ្នកនិពន្ធត្រូវតែសរសេរតែពីការពិត និងយោងទៅលើប្រភពព័ត៌មាន ដែលគួរជឿជាក់បំផុត ដូចជាព័ត៌មានសម្ងាត់ របស់ក្រសួងការបរទេសអាមេរិក។

ប្រភពនោះ ត្រូវបានប្រើប្រាស់ ដើម្បីសម្អាតឧក្រិដ្ឋកម្មរបស់សហរដ្ឋអាមេរិកកន្លងមក នៅក្នុងឥណ្ឌូចិន និងបង្កើតជាមូលដ្ឋាន ដែលបណ្តាលឲ្យមានអំពើឧក្រិដ្ឋកម្មថ្មីៗ និងព្រៃផ្សៃ នៅអាមេរិកកណ្តាល ដោយសារតែសហរដ្ឋអាមេរិក ត្រូវតែបញ្ឈប់ «ពួក ប៉ុល ពត ដែលនៅសេសសល់»។ យើងបានប្រៀបធៀបកម្ពុជា ជាមួយនឹងទីម័រខាងកើត ដែលជាអំពើព្រៃផ្សៃ ក្នុងរយៈពេលតែមួយ និងក្នុងតំបន់តែមួយ នៅលើពិភពលោក។ នៅទីម័រខាងកើត សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្ត ទទួលខុសត្រូវជាចម្បង លើអំពើព្រៃផ្សៃ ហើយអាចបញ្ឈប់អំពើព្រៃផ្សៃនេះយ៉ាងងាយស្រួល។ នៅប្រទេសកម្ពុជាវិញ ពួកគេអាចធ្វើបានតិចតួច ឬមិនអាចធ្វើអ្វីសោះ ហើយអំពើព្រៃផ្សៃរបស់សត្រូវអាចយកមកប្រើ ដើម្បីបង្ហាញថា អំពើរបស់យើងជាអំពើត្រឹមត្រូវ។

នៅពេលលោកពិនិត្យមើលព្រឹត្តិការណ៍ប្រល័យពូជសាសន៍ ក្រោមស្នាដៃខ្មែរក្រហម ដែលបានកើតឡើង នៅក្នុងប្រទេសកម្ពុជា តើលោកស្តីបន្ទោសការទម្លាក់គ្រាប់បែករបស់អាមេរិកនៅកម្ពុជា ថាបានបង្កើតស្ថានការណ៍ ដែលផ្តល់ឱកាសឲ្យ ប៉ុល ពត ឡើងកាន់អំណាច ឬវាជាព្រឹត្តិការណ៍ ដែលមានលក្ខណៈស្មុគស្មាញជាងនេះ?

បណ្ឌិតដែលសិក្សា អំពីប្រទេសកម្ពុជាសំខាន់ៗ ពីររូប គឺលោក អូរិន ថេល័រ និងលោក បេន ឃៀរណាន បានបង្ហាញថា នៅពេលការទម្លាក់គ្រាប់បែកយ៉ាងខ្លាំងក្លា ពីសំណាក់អាមេរិក ទៅលើតំបន់ជនបទ ក្នុងប្រទេសកម្ពុជា បានចាប់ផ្តើម កងទ័ពខ្មែរក្រហម គ្រាន់តែជាក្រុមតូចមួយ ដែលមានកម្លាំងប្រមាណ ១ ម៉ឺននាក់ប៉ុណ្ណោះ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយមក ខ្មែរក្រហម បានរីកលូតលាស់ ក្លាយជាក្រុមយោធាធំមួយ ដែលមានកងទ័ពជាង ២០ ម៉ឺននាក់ ដែលកាន់តែអាក្រក់ទៅៗ និងប៉ុនប៉ងធ្វើការសងសឹក។ យុទ្ធនាការឃោសនា កេណ្ឌកងទ័ព របស់ពួកគេ បានបញ្ចូលការទម្លាក់គ្រាប់បែក របស់អាមេរិក បានយ៉ាងជោគជ័យ។ របាយការណ៍មន្ទីរបញ្ចកោណ បានលាតត្រដាងឲ្យដឹងថា គ្រាប់បែករាប់ពាន់តោន ដែលត្រូវបានទម្លាក់នៅតំបន់ជនបទ ក្នុងប្រទេសកម្ពុជា ប្រហាក់ប្រហែលនឹងចំនួនគ្រាប់បែកសរុប ដែលអាមេរិក បានទម្លាក់នៅតំបន់មហាសមុទ្រប៉ាស៊ីហ្វិក ក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ហើយប្រាកដណាស់ វាមានលក្ខណៈខ្លាំងក្លាជាង។ ប៉ុន្តែ វាពិតណាស់ មិនមែនជាកត្តាតែមួយគត់នោះទេ។

តាមរយៈការអានប្រវត្តិសាស្ត្ររបស់លោក តើហេតុអ្វី បានជាមេដឹកនាំនៃរដ្ឋនានា ប្រព្រឹត្តខុសធ្ងន់ធ្ងរ មានដូចជាសម្លាប់នរណាម្នាក់ ដែលកំពុងរៀននៅក្នុងសាលា ឬអ្នកដែលពិការជាដើម? តើលោកអាចប្រមើលមើលមូលដ្ឋានបញ្ញា ឬអារម្មណ៍ ថាតើជនល្មើស នៃការសម្លាប់រង្គាល អាចរស់នៅដោយពុំខ្វល់ខ្វាយអ្វី ក្នុងនាមជាឧបករណ៍ នៃការសម្លាប់រង្គាលបានយ៉ាងដូចម្តេច?

នេះជាសំណួរល្អណាស់។ យើងក៏អាចសួរសំណួរស្រដៀងគ្នានេះ អំពីសង្គមរបស់ខ្លួនយើង ដែលយើងគួរតែអាចយល់ដឹងបានប្រសើរជាងនេះ។ និយាយពីកម្ពុជាវិញ ការទម្លាក់គ្រាប់បែកខ្លាំងក្លា ចាប់ផ្តើមក្រោមបញ្ជារបស់ប្រធានាធិបតីនិកសុន ដែលលោកឃីស៊ីងជើ បានបញ្ជូនសារ ទៅយោធាអាមេរិក ដោយពាក្យសម្តីថា «យុទ្ធនាការទម្លាក់គ្រាប់បែកដ៏ច្រើននៅកម្ពុជា។ អ្វីដែលហោះនៅលើអ្វីដែលធ្វើចលនា»។ នេះជាប្រភេទនៃការអំពាវនាវឲ្យមានអំពើប្រល័យពូជសាសន៍ ដែលកម្រមាននរណាម្នាក់មើលឃើញក្នុងឯកសារសំខាន់របស់រដ្ឋណាមួយណាស់។ ពាក្យសម្តីទាំងនេះ ត្រូវបានបោះពុម្ពផ្សាយ នៅលើកាសែតញូវយ៉កថែមស៍ ហើយវាពុំមានប្រតិកម្មក្នុងចំណោមអ្នកអានបញ្ញវន្ត ដែលមានគំនិតទូលំទូលាយភាគច្រើនរបស់វាឡើយ ហើយអ្នកអានមួយចំនួនថែមទាំងចងចាំវាទុកទៀតផង។


លោកណូអាម ឈុំស្គី ថតកាលពីដើមឆ្នាំនេះ។ COURTESY OF MEDIAS

តើជនល្មើស ប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅកម្ពុជា គួរតែត្រូវគេនាំយកមកកាត់ទោស ហើយប្រហារជីវិត ឬដាក់ពន្ធនាគារដែរឬទេ? ហេតុអ្វី?

ខ្ញុំជំទាស់ទៅនឹងទោសប្រហារជីវិត តែខ្ញុំគិតថា ពួកគេ គួរតែទទួលការកាត់ក្តី និងផ្តន្ទាទោសដោយយុត្តិធម៌។ ពុំមាននរណាម្នាក់សួរសំណួរនេះ អំពីលោក និកសុន ឬលោកឃីស៊ីងជើ ឬអំពីអ្នកមានទ្រព្យធន និងអ្នកមានអំណាចជាទូទៅឡើយ។

តើហេតុអ្វី បានជាលោកគិតថា ប្រទេសចិន គាំទ្រខ្មែរក្រហម ហើយក្រោយមក វាយប្រហារវៀតណាមខាងជើង បន្ទាប់ពីវៀតណាម បានឈ្លានពានចូលកម្ពុជានៅឆ្នាំ ១៩៧៩? ដើម្បីមូលហេតុរដ្ឋមែនទេ? តើចិន បានផ្លាស់ប្តូរយ៉ាងដូចម្តេចខ្លះ ក្នុងរយៈពេល ៣០ ឆ្នាំចុងក្រោយនេះ ហើយតើយើងអាចទស្សន៍ទាយបានអ្វីខ្លះ ដែលនឹងអាចកើតមាន នៅក្នុងទំនាក់ទំនងរបស់ចិនជាមួយប្រទេសភូមិផងរបងជាមួយ ក្នុងតំបន់អាស៊ីអាគ្នេយ៍នោះ?

គូសត្រូវជាប្រវត្តិសាស្ត្រ រវាងចិន និងវៀតណាម មានតាំងពីរាប់ពាន់ឆ្នាំមុនមក។ នៅចន្លោះឆ្នាំ ១៩៧៨-១៩៧៩ កម្ពុជាគឺជាសម្ព័ន្ធមិត្តរបស់ចិន ហើយវៀតណាម ត្រូវបានភ្ជាប់ទៅនឹងរុស្ស៊ី ដែលជាសត្រូវដ៏ចម្បងរបស់ចិន។ ការឈ្លានពានរបស់ចិន លើវៀតណាម ដែលគាំទ្រដោយអាមេរិក មានគោលបំណងច្បាស់ក្រឡែតថា ជាការដាក់ទណ្ឌកម្មដល់ជនជាតិវៀតណាម។ ដូចដែលអ្នកបានដឹងស្រាប់ហើយ អាមេរិក និងអង់គ្លេស ភ្លាមៗ បានងាកទៅគាំទ្រ ប៉ុល ពត (កម្ពុជាប្រជាធិបតេយ្យ) ទាំងផ្នែកយោធា ការទូត និងមនោគមន៍វិជ្ជា។ ពិភពលោក បានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ក្នុងរយៈពេល ៣០ ឆ្នាំចុងក្រោយនេះ។ សហភាពសូវៀត បានដួលរលំ ចិនបានឈានដល់ដំណាក់កាលមួយ ដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចខ្លាំង ដែលវៀតណាមបច្ចុប្បន្នកំពុងតែតាមពីក្រោយ ក្នុងលក្ខណៈតូចជាង។ ភាពកាច់កុងគ្នា និងភាពតានតឹង នៅតែមាន តែពួកគេពុំបានប្រើប្រាស់ទម្រង់ដែលពួកគេ មាននៅក្នុងអំឡុងពេលមានអរិភាពខ្លាំង រវាងចិន និងរុស្ស៊ីឡើយ។

តើលោកយល់ថា ហេនរី ឃីស៊ីងជើ គួរតែត្រូវគេនាំយកឡើងតុលាការ ពីបទទម្លាក់គ្រាប់បែកនៅកម្ពុជាដែរឬទេ? តើលោកគិតថា កងកម្លាំងខ្មែរក្រហម នៅតែជាកម្លាំងនៅក្រៅឆាក ហើយនឹងមិនអាចមានឱកាស បានឡើងកាន់អំណាចដឹកនាំប្រទេសកម្ពុជាឡើយ ប្រសិនបើការទម្លាក់គ្រាប់បែករបស់អាមេរិក មកលើកម្ពុជា មិនកើតឡើងទេនោះ? តើសហរដ្ឋអាមេរិក ជំពាក់ការសុំទោសកម្ពុជា ចំពោះការទម្លាក់គ្រាប់បែកនោះមែន ទេ?

នៅក្នុងពិភពដែលគ្រប់គ្រងដោយយុត្តិធម៌ មិនមែនកម្លាំងបាយ លោកឃីស៊ីងជើ ប្រាកដណាស់ត្រូវគេនាំឡើងតុលាការ មិនមែនគ្រាន់តែចំពោះឧក្រិដ្ឋកម្មលាក់បាំងនៅកម្ពុជានោះទេ។ ដូចដែលខ្ញុំបានលើកឡើងមុននេះ វារួមចំណែក ដល់ការឡើងកាន់អំណាចរបស់ខ្មែរក្រហម ខណៈការសម្លាប់មនុស្ស មិនដឹងចំនួនពិត និងបន្សល់ទុក នូវការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ។ ផលប៉ះពាល់របស់វាធ្ងន់ធ្ងរខ្លាំងណាស់ រហូតដល់មន្ត្រីជាន់ខ្ពស់អាមេរិកទស្សន៍ទាយថា មនុស្សមួយលាននាក់ អាចនឹងបាត់បង់ជីវិត ក្រោយសង្គ្រាមបញ្ចប់នៅឆ្នាំ ១៩៧៥ ហើយថារយៈពេលជាងពីរឆ្នាំ នៃការធ្វើការងារដូចទាសករ នៅក្នុងរបបខ្មែរក្រហម នឹងត្រូវការចាំបាច់ ការស្តារឡើងវិញ នៃដំណើរការសង្គមនៅកម្ពុជា។ សរុបទៅ អាមេរិក មិនត្រឹមតែជំពាក់កម្ពុជា តែការសុំទោសប៉ុណ្ណោះនោះទេ តែអាមេរិក ជំពាក់ការជួសជុលកម្ពុជាឡើងវិញ ដែលខ្ទេចខ្ទាំដោយការទម្លាក់គ្រាប់បែក៕

ប្រែសម្រួលៈលីម គួង និងជាវង់ សុគារិទ្ធ ■